**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិ**
**រៀបចំបុណ្យជាតិ-អន្តរជាតិ**
លេខៈ ០៤៤/២០២៥ គជបអ

# ផែនការណែនាំ
## ស្តីពី
## ការរៀបចំប្រារព្ធពិធីគោរពរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
## រំលឹកខួបលើកទី៣២ឆ្នាំ "ទិវាប្រកាសរដ្ឋធម្មនុញ្ញ"

**យោង**: - ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១២០៤ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- ព្រះរាជក្រឹត្យលេខ នស/រកត/១០២៤/១២៦៦ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៤ ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- អនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- អនុក្រឹត្យលេខ២០៤ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤ ស្តីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ២០២៥
- សារាចរណែនាំលេខ ០១ សរ ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០២៥ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំប្រារព្ធពិធីគោរពរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្នុងស្មារតីនៃការរំលឹកខួប "ទិវាប្រកាសរដ្ឋធម្មនុញ្ញ"។

ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ជាទិវាប្រវត្តិសាស្ត្រ ដែលរដ្ឋធម្មនុញ្ញជាច្បាប់កំពូល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបាន **ព្រះមហាក្សត្រ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើជាផ្លូវការក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ក្រោយសភាធម្មនុញ្ញបានអនុម័ត តាមឆន្ទៈរួមនៃប្រជារាស្ត្រខ្មែរ ដែលបានក្រោកឈរឡើង ប្តូរផ្តាច់ រួបរួមគ្នា ក្នុងការការពារជាតិ សាសនា ព្រះមហាក្សត្រ ការពង្រឹងឯករាជ្យជាតិ រក្សាការពារទឹកដីកម្ពុជា អធិបតេយ្យថ្លៃថ្លា អារ្យធម៌អង្គរដ៏បវរ និងកសាងប្រទេសជាតិឱ្យបានឈានឡើងរីកចម្រើន លូតលាស់ សម្បូររុងរឿងជានិច្ចនិរន្តរ៍។

ការអនុវត្តរដ្ឋធម្មនុញ្ញរយៈពេលជាង៣០ឆ្នាំកន្លងមក ក្រោមម្លប់នៃសុខសន្តិភាព និងឯកភាពជាតិ អាស្រ័យដោយមាននយោបាយឈ្នះ ឈ្នះ របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី បច្ចុប្បន្នជាប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា បានធ្វើឱ្យសម្រេចសមិទ្ធផលធម្មនុញ្ញដ៏ធំធេងលើគ្រប់វិស័យ ប្រកបដោយភាពជោគជ័យត្រចះ



វិថីឧកញ៉ា ឈុន កែងតិវិថីព្រះស៊ីសុវត្ថិ ទល់មុខសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ E-mail: nconif@gmail.com Phone: 012 912 265 / 097 97 69 111

គ្រចង់ ដែលធ្វើឱ្យប្រជារាស្ត្រកំពុងរស់នៅក្នុងសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍ រីកចម្រើនឥតឈប់ឈរ ក្រោមមាគ៌ាដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជា និងក្រោមម្លប់ដ៏ត្រជាក់ នៃ**អង្គព្រះមហាក្សត្រ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។

ដើម្បីរំលឹកដល់ថ្ងៃទី២៤ កញ្ញា ១៩៩៣ ដែលជាថ្ងៃប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ស្របតាមគោលបំណង និងសំណូមពររបស់រាជរដ្ឋាភិបាល ដែលបានកំណត់យកថ្ងៃទី២៤ ខែកញ្ញា ជារៀងរាល់ឆ្នាំ ដើម្បីប្រារព្ធពិធីគោរពរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សូមធ្វើការណែនាំដូចតទៅ ៖

* **<u>គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ</u>**

រៀបចំកម្មវិធីជូនគណៈប្រតិភូថ្នាក់ដឹកនាំ និងមន្ត្រីរាជការ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងរដ្ឋបាលរាជធានីភ្នំពេញ អញ្ជើញទៅចូលរួមដាក់កម្រងផ្កាប្រារព្ធពិធីគោរពរដ្ឋធម្មនុញ្ញ នៅនីតិបូជនីយដ្ឋាន វិមានរដ្ឋធម្មនុញ្ញ នាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៥។

* **<u>គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងរដ្ឋបាលរាជធានីភ្នំពេញ</u>**

រៀបចំគណៈប្រតិភូថ្នាក់ដឹកនាំ និងមន្ត្រីរាជការអញ្ជើញ ចូលរួមប្រារព្ធ ពិធីគោរពរដ្ឋធម្មនុញ្ញ នៅនីតិបូជនីយដ្ឋាន វិមានរដ្ឋធម្មនុញ្ញ នាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៥ ចាប់ពីម៉ោង៧:០០ នាទីព្រឹកតទៅ។

រៀបចំតុបតែងលម្អដោយមានបំភ្លឺភ្លើងពណ៌ លើកទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ និងបដាពាក្យស្លោក ឱ្យបានសមរម្យ នៅមុខក្រសួង ស្ថាប័ន។

* **<u>រដ្ឋបាលរាជធានី ខេត្ត</u>**

ត្រូវរៀបចំប្រារព្ធពិធីគោរពរដ្ឋធម្មនុញ្ញ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៥ ឱ្យបានស័ក្តិសម ដោយជ្រើសរើសទីតាំងណាមួយស័ក្តសម ។

រៀបចំតុបតែងលម្អដោយមានបំភ្លឺភ្លើងពណ៌ លើកទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ បដាពាក្យស្លោក ណែនាំតាមបណ្តាមន្ទីរ អង្គភាព ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ គ្រឹះស្ថានសិក្សា ក្រុមហ៊ុន រោងចក្រ សហគ្រាស គ្រឹះស្ថានសាធារណៈ សាលារៀន និងគ្រប់វត្តអារាម មណ្ឌលវិបស្សនា អាស្រមព្រះពុទ្ធសាសនា ពាហិរសាសនា ព្រមទាំងបំផុសប្រជាពលរដ្ឋ ឱ្យលើកទង់ជាតិគ្រប់គេហដ្ឋាន។

* **<u>ក្រសួងព័ត៌មាន</u>**

រៀបចំកម្មវិធីផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ជាតិ និងឯកជន ព្រមទាំងបណ្តាញផ្សព្វផ្សាយនានា ឱ្យបានទូលំទូលាយនូវរដ្ឋធម្មនុញ្ញ និងប្រវត្តិទាក់ទងនឹងការបង្កើតរដ្ឋធម្មនុញ្ញ ក្នុងគោលដៅបំផុសស្មារតីគោរព ការពារ លើកតម្កើង និងប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ជាតិ។

* **<u>ក្រសួងសុខាភិបាល</u>**

ចាត់វេជ្ជបណ្ឌិត រថយន្តគិលានសង្គ្រោះ និងឱសថសម្រាប់បម្រើសុខុមាលភាព ជូនដល់គណៈប្រតិភូ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងរដ្ឋបាលរាជធានីភ្នំពេញ អញ្ជើញចូលរួមប្រារព្ធពិធីគោរពរដ្ឋធម្មនុញ្ញ នៅនីតិបូជនីយដ្ឋាន វិមានរដ្ឋធម្មនុញ្ញ នាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៥ ចាប់ពីម៉ោង៦:០០ នាទី។

*** <u>ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ</u>**

ណែនាំគ្រប់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ រាជធានី ខេត្ត ចាត់ក្រុមតន្ត្រីសិល្បៈបុរាណ សម័យ សម្តែង ជូនប្រជារាស្ត្រទស្សនាកម្សាន្តសប្បាយ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៥ តាមទីសាធារណៈ ដើម្បីចូលរួមអបអរសាទរក្នុងទិវាជាប្រវត្តិសាស្ត្រនេះ។

*** <u>ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ</u>**

ជួយបង្កលក្ខណៈងាយស្រួលដោះស្រាយសម្ភារៈ ថវិកា សម្រាប់បម្រើការរៀបចំប្រារព្ធពិធីគោរពរដ្ឋធម្មនុញ្ញ នៅនីតិបូជនីយដ្ឋាន វិមានរដ្ឋធម្មនុញ្ញ ឱ្យបានសមស្រប និងទាន់ពេលវេលា។

គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សង្ឃឹមនិងជឿជាក់ថា ថ្នាក់ដឹកនាំគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត នឹងអនុវត្តតាមស្មារតី នៃផែនការណែនាំនេះ ឱ្យបានសម្រេចលទ្ធផលល្អប្រសើរ។

ថ្ងៃព្រហស្បតិ៍ ១កើត ខែ ភិទ្រុក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ២០២៥

**ជ.គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ**

**ប្រធាន**

**សម្តេចមហាមន្ត្រី គុយ សុផល**

**<u>កន្លែងទទួល</u> ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
  "ដើម្បីជូនជ្រាប"
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ពាក្យស្លោក

## សម្រាប់ប្រើក្នុងការរៀបចំប្រារព្ធពិធីគោរពរដ្ឋធម្មនុញ្ញ
## នៃព្រះរាជាណាចក្រកម្ពុជា រំលឹកខួបលើកទី៣២ឆ្នាំ "ទិវាប្រកាសរដ្ឋធម្មនុញ្ញ"
## ២៤ កញ្ញា ២០២៥

១- ជយោ! ព្រះរាជាណាចក្រកម្ពុជា

២- ជាតិ សាសនា ព្រះមហាក្សត្រ

៣- អបអរសាទរពិធីគោរពរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្នុងស្មារតីនៃការរំលឹកខួប "ទិវាប្រកាសរដ្ឋធម្មនុញ្ញ"

៤- ទិវារំលឹកខួបលើកទី៣២ឆ្នាំ នៃការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

៥- ជយោ! សន្តិភាព និងអភិវឌ្ឍន៍

៦- មានសន្តិភាព ទើបមានការអភិវឌ្ឍប្រទេសជាតិ

៧- ជយោ! សន្តិភាព និងការបង្រួបបង្រួមជាតិ

៨- ជយោ! សន្តិភាព ដោយនយោបាយ ឈ្នះ ឈ្នះ

៩- ជយោ! នយោបាយ ឈ្នះ ឈ្នះ នាំមកនូវសន្តិភាព

១០- សូមអរគុណសន្តិភាព ក្រោមការដឹកនាំរបស់ សម្តេចតេជោ ហ៊ុន សែន

១១- ជយោ! សន្តិភាព ប្រជាធិបតេយ្យ និងអភិវឌ្ឍន៍

១២- ពលរដ្ឋគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

១៣- ការពារដាច់ខាត រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

១៤- ជយោ! លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស នៅព្រះរាជាណាចក្រកម្ពុជា